**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation – Religion – King

**ក្រសួងពាណិជ្ជកម្ម**

Ministry of Commerce

No. **៣៧១៨** MOC / SM 2009

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៩

**<u>សូមគោរពជូន</u>**

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងព័ត៌មាន**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងទេសចរណ៍**
- **លោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
- **ឯកឧត្តមរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**
- **លោកជំទាវរដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសុខាភិបាល**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា**
- **ឯកឧត្តមរដ្ឋទេសាភិបាលធនាគារជាតិ នៃកម្ពុជា**
- **ឯកឧត្តមរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**
- **ឯកឧត្តមរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**
- **ឯកឧត្តមអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល អភិបាលរាជធានីភ្នំពេញ**
- **ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត គ្រប់ខេត្ត**

**កម្មវត្ថុ** : ការផ្តើមអនុវត្តន៍កិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជប៉ុន ។

**ជូនភ្ជាប់** : កិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋសមាជិកអាស៊ាន និងជប៉ុន ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា កិច្ចព្រមព្រៀងស្តីពីភាពជា ដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋសមាជិកអាស៊ាន និងជប៉ុន ត្រូវបានចរចាចប់សព្វគ្រប់ និងចុះហត្ថលេខាក្នុងឆ្នាំ ២០០៨ ។ រដ្ឋសភាកម្ពុជាបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនេះនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩ ហើយព្រះមហាក្សត្រកម្ពុជាបានឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងនេះនៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៩ ។ យោងតាមការព្រមព្រៀងរវាងកម្ពុជា-ជប៉ុន លើកទី២ ថ្ងៃទី ២៤-២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កិច្ចព្រមព្រៀងនេះនឹងត្រូវចូលជាធរមានចាប់ពី **ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០** តទៅ ។ អត្ថប្រយោជន៍ដែលកម្ពុជានឹង ទទួលបានរួមមាន :

-ការនាំចេញ-នាំចូលនៅក្នុងតំបន់ នឹងទទួលអត្រាពន្ធគយទាប

-មិនមានរបាំងពាណិជកម្មចំពោះការនាំចេញ-នាំចូល

-ការប្រកួតប្រជែងមានភាពស្មើគ្នា

-កម្ពុជាអាចយកធាតុផ្សំពីបណ្តាលប្រទេសសមាជិកអាស៊ានមកផលិតទំនិញសំរាប់នាំចេញបាន ។

-ក្រសួងពាណិជកម្ម នឹងចេញវិញ្ញាបនប័ត្រប្រភពដើមទំនិញ **From AJ** ជូនធុរជន ដែលមានបំណងប្រើប្រាស់វិញ្ញាបនប័ត្រនេះសម្រាប់នាំទំនិញទៅប្រទេសជប៉ុន ។

អាស្រ័យហេតុនេះសូម **ឯកឧត្តម** មេត្តាជ្រាប និងផ្សព្វផ្សាយព័ត៌មាន ស្តីពីការចាប់ផ្តើមអនុវត្តន៍នេះតាមការគួរ ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជកម្ម**

**ចម ប្រសិទ្ធ**

***ចំលងជូន :***

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ ម៉ែន សំអន
- អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
- ឯកសារ-កាលប្បវត្តិ